ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៥ រ៉ែ.ឧអធរ.សជណ

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**
**ជម្រាបមក**
**លោកប្រធានក្រុមហ៊ុន អេច.ធី ឃ័ង យី (ខេមបូឌា) ឌីវេឡុបមិន ឯ.ក**
(**ក្រុមហ៊ុន** H.T KUANG YE (CAMBODIA) DEVELOPMENT CO., LTD.)

**កម្មវត្ថុ** ៖ សេចក្តីជូនដំណឹងស្តីពីការប្រកាសលទ្ធផលក្រុមហ៊ុនដែលត្រូវបានជ្រើសរើស ដើម្បីបន្តអនុវត្តនីតិវិធីនៅក្នុងការផ្តល់អាជ្ញាបណ្ណស្វែងរុករករ៉ែលោហៈនៅតំបន់ចំនួន ០២ទីតាំង ក្នុងខេត្តស្ទឹងត្រែង ។

**យោង** ៖ សេចក្តីជូនដំណឹងលេខ ០២៤ រ៉ែ.ឧអធរ.សជណ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកប្រធានក្រុមហ៊ុន** ជ្រាបថា ក្រុមហ៊ុនរបស់លោកត្រូវបានជ្រើសរើសជាក្រុមហ៊ុនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសិទ្ធិអាទិភាព ដើម្បីបន្តអនុវត្តនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណស្វែងរុករកធនធានរ៉ែនៅតំបន់ដូចខាងក្រោម៖

១.តំបន់ព្រែកកេងកង ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ទំហំ ៤៩,២៥ គីឡូម៉ែត្រក្រឡា និង
២.តំបន់ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ទំហំ ៣២ គីឡូម៉ែត្រក្រឡា ។

ទទួលបានសេចក្តីជូនដំណឹងនេះ លោកប្រធានក្រុមហ៊ុនត្រូវបិទផ្សាយនៅទីស្នាក់ការអាជ្ញាធរឃុំដែលតំបន់សម្បទាននេះស្ថិតនៅ និងអញ្ជើញមកទំនាក់ទំនងជាមួយនាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធានរ៉ែ នៅរៀងរាល់ម៉ោងធ្វើការដើម្បីពិនិត្យ និងពិភាក្សាអំពីនីតិវិធីដែលត្រូវអនុវត្តបន្តក្នុងរយៈពេលយ៉ាងយូរ **១៥(ដប់ប្រាំ)**ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃលិខិតនេះ ។

ផុតរយៈពេលកំណត់ខាងលើនេះ ក្នុងករណីក្រុមហ៊ុនរបស់លោកពុំបានចូលមកទំនាក់ទំនងបន្តនីតិវិធីស្របតាមការកំណត់ទេនោះ ក្រសួងរ៉ែ និងថាមពលចាត់ទុកថា ក្រុមហ៊ុនរបស់លោកបានបោះបង់ចោលសិទ្ធិអាទិភាពរបស់ខ្លួនក្នុងការទទួលបានអាជ្ញាបណ្ណស្វែងរុករករ៉ែនេះ។

អាស្រ័យហេតុនេះ សូម **លោកប្រធានក្រុមហ៊ុន** ជ្រាប និងយកចិត្តទុកដាក់អនុវត្តឱ្យបានទាន់ពេលវេលា។

សូម **លោកប្រធានក្រុមហ៊ុន** ទទួលនូវការគោរពរាប់អានពីខ្ញុំ។

ស៊ុយ សែម